ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៤ សសរ

# សេចក្តីសំរេច

## ស្តីពីកំណែតំរូវឈ្មោះគណៈកម្មការដឹកនាំការងារអភិវឌ្ឍន៍ផ្នែកឯកជន និងការបន្ថែមសមាសភាពសមាជិកនៃអនុគណៈកម្មាធិការសហគ្រាសធុនតូច និងមធ្យម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៥ ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងសម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ជាទីប្រឹក្សាពិសេសរបស់រាជរដ្ឋាភិបាល និងជាសហប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០៣ /នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី ២៤ ខែ មិនា ឆ្នាំ ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញសេចក្តីសំរេចលេខ ៤៤ សសរ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការបង្កើតគណៈកម្មការដឹកនាំការងារ ដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន
- អនុលោមតាមតំរូវការចាំបាច់នៃការងារ

## សំរេច

**ប្រការ១:** ត្រូវបានកែតំរូវឈ្មោះ " គណៈកម្មការដឹកនាំការងារដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន " ដែលមានចែងក្នុងសេចក្ដីសំរេចលេខ ៤៤ សសរ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៤ ជា " គណៈកម្មាធិការដឹកនាំការងារដើម្បីអភិឌ្ឍន៍ផ្នែកឯកជន " ។ រាល់ពាក្យ " គណៈកម្មការ " ដែលមានចែងក្នុងសេចក្ដីសំរេចលេខ ៤៦ សសរ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ ២០០៤ ត្រូវបានជំនួសដោយពាក្យ " គណៈកម្មាធិការ " ។ ឯពាក្យ " អនុគណៈកម្មការ " ដែលមានចែងក្នុងសេចក្ដីសំរេចលេខ ៤៦ សសរ ត្រូវបានជំនួសដោយពាក្យ " អនុគណៈកម្មាធិការ " ។

**ប្រការ២:** ត្រូវបានបន្ថែមសមាសភាពសមាជិកអនុគណៈកម្មាធិការសហគ្រាសធុនតូច និងមធ្យម ដូចតទៅ:

១- ឯកឧត្ដម **ពេជ សោភ័ន** រដ្ឋលេខាធិការនៃក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ

២- ឯកឧត្ដម **អ៊ិន ចន្ធា** រដ្ឋលេខាធិការ នៃក្រសួងអភិវឌ្ឍន៍ជនបទ

**ប្រការ៣:** សេចក្ដីសំរេចណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្ដីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៤:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ២ ខាងលើ ត្រូវអនុវត្តសេចក្ដីសំរេចនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី... ខែ សីហា ឆ្នាំ ២០០៥

**ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចប្រការ២ និងប្រការ៤
- ឯកសារ- កាលប្បវត្តិ